# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


០៩-៨-២០១៦ -ព្រះរាជក្រម នស/រកម/០៨១៦/០១២ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី ៧ និងទី ៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពី សេវាកម្ម ៧៣៦៩


### ២. ព្រះរាជក្រឹត្យ


១៥-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៧៤ ស្តីពី ការផ្ទេរបញ្ចូលក្របខ័ណ្ឌ និងដំឡើងឋានន្តរស័ក្តិ ជាករណីពិសេសដល់លោក **អេង មោរា** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ៧៤០៩

១៥-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៧៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **អ៊ីរិក ម៉ៃឆែល ស្ស៉ង់សែល** (ERIC, MICHEL CHANCEL) ជនជាតិបារាំង សញ្ជាតិបារាំង ៧៤១០

១៥-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៧៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជុង ឈីងយាន** (CHUANG CHING-YUAN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៧៤១១

១៥-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៧៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជុង ចេងហ្សៀន** (CHUANG CHENG-HSIEN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៧៤១២

១៥-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៧៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អស់លោក ចំនួន ០៤ រូប និងគ្រឹះស្ថានសិក្សា ចំនួន ០១ ៧៤១៣

១៥-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៧៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា លោកជំទាវ អស់លោក លោកស្រី និងសាស្ត្រាចារ្យ ចំនួន ៨០ រូប ៧៤១៤

២២-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៨០ ស្តីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខេត្តឧត្តរមានជ័យ ជាមួយខេត្តព្រះវិហារ ដោយកាត់យកផ្ទៃដីទំហំ ២០.៩២៤ ហិកតា ពីឃុំស្រអែម និងឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មកឱ្យឃុំព្រះប្រឡាយ ឃុំបាក់អន្លូង និងឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ៧៤១៦

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

២៥-៨-២០១៦ -សេចក្តីសម្រេចលេខ ៤៦/២០១៦ កបធ.សសរ ស្តីពី វិសោធនកម្មប្រការ ៨ ថ្មី (ពីរ) និងប្រការ ១០ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុង ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ៧៤១៩

## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១៨-៨-២០១៦ -អនុក្រឹត្យលេខ ៨៩៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៤២១

២២-៨-២០១៦ -អនុក្រឹត្យលេខ ៩០០ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៧៤២២

២២-៨-២០១៦ -អនុក្រឹត្យលេខ ៩០១ អនក្រ.តត ស្តីពី ការបង្គាប់ឱ្យធ្វើបត្យាប័ន ៧៤២៤

២៣-៨-២០១៦ -អនុក្រឹត្យលេខ ៩០២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៤២៦

២៣-៨-២០១៦ -អនុក្រឹត្យលេខ ៩០៣ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៤២៧

២៤-៨-២០១៦ -អនុក្រឹត្យលេខ ៩០៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៤២៨

២៤-៨-២០១៦ -អនុក្រឹត្យលេខ ៩០៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៤៣៤

២៤-៨-២០១៦ -អនុក្រឹត្យលេខ ៩០៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៤៣៧

២៦-៨-២០១៦ -អនុក្រឹត្យលេខ ៩០៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៤៣៨

### ២~សេចក្តីសម្រេច

២៩-៨-២០១៦ -សេចក្តីសម្រេចលេខ ៩៣ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៧៤៣៩

## IV~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២១-៧-២០១៦ - សេចក្ដីសម្រេចលេខ ០៣៨ សហវ ស្ដីពី ការបង្កើតក្រុមការងារដោះស្រាយវិវាទ ពាក់ព័ន្ធការកាន់កាប់ដីរដ្ឋ ដែលស្ថិតក្រោមការប្រើប្រាស់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកោះកុង ដោយមន្ត្រី ០២ រូប នៃរតនាគារខេត្តកោះកុង ៧៤៤១

២១-៧-២០១៦ - សេចក្ដីសម្រេចលេខ ០៤០ សហវ ស្ដីពី ការតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតថ្នាក់ដឹកនាំអង្គភាពថវិកា ៧៤៤៤

២១-៧-២០១៦ -សេចក្ដីសម្រេចលេខ ០៤១ សហវ ស្ដីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពក្រុមការងារថវិកា កម្រិតផ្ទៃក្នុងអង្គភាពថវិកា ៧៤៤៧

០៨-៨-២០១៦ -ប្រកាសលេខ ៩០៤ សហវ.ប្រក ស្ដីពី ការលើកទឹកចិត្តពន្ធដារចំពោះគ្រឹះស្ថានសិក្សា ៧៤៥៤

០៩-៨-២០១៦ -ប្រកាសលេខ ៩០៩ សហវ.ប្រក ស្ដីពី ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៧៤៥៨

១៧-៨-២០១៦ -ប្រកាសលេខ ០០៤/១៦ គ.ម.ក.ប្រក ស្ដីពី ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការ ផ្ដល់សន្ទនីយភាពមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ៧៤៦១


### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


០៦-៦-២០១៦ -ប្រកាសលេខ ២៩៥ ឧស.កឧ.ប្រក.០៦ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឥណ្ឌូចិន អ៊ីភែរីល (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៧៤៦៨

០៦-៦-២០១៦ -ប្រកាសលេខ ២៩៦ ឧស.កឧ.ប្រក.០៦ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ធី ខេ ឈិន ហ្វូ បង្កើតរោងចក្រ ផលិតប្រដាប់ព្យួរសម្លៀកបំពាក់ និងផលិតផលពីប្លាស្ទិក ៧៤៧១

០៦-៦-២០១៦ -ប្រកាសលេខ ២៩៧ ឧស.កឧ.ប្រក.០៦ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាដារ៉េ (ខេមបូឌា) បង្កើតរោងចក្រ ប៉ាក់ និងកាត់ដេរសម្លៀកបំពាក់ ៧៤៧៤

០៦-៦-២០១៦ -ប្រកាសលេខ ២៩៨ ឧស.កឧ.ប្រក.០៦ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វៃរដុង (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ស្រោមដៃ កន្សែងបង់កមួក ៧៤៧៧

០៦-៦-២០១៦ -ប្រកាសលេខ ២៩៩ ឧស.កឧ.ប្រក.០៦ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តិក សាង បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ៧៤៨០

| | | |
|---|---|---|
| ១៣-៦-២០១៦ | -ប្រកាសលេខ ៣០១ ឧស.កឧ.ប្រក.០៦ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្ស៊ូ ឈុន ស៊ូ បង្កើតរោងចក្រ ផលិតស្បែកជើង | ៧៤៨៣ |
| ១៥-៦-២០១៦ | -ប្រកាសលេខ ៣០៨ ឧស.កឧ.ប្រក.០៦ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អាយឌាល ផេស៊ីហ្វិក (ខេមបូឌា) បង្កើតរោងចក្រ ផលិតកាបូប និងបន្តោងសោគ្រប់ប្រភេទ | ៧៤៨៦ |

# ព្រះរាជក្រម

នស/រកម/០៨១៦/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី ៧ និងទី ៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី ៧ និងទី ៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី ៧ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ និងពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី ៨ នៅទីក្រុងប៉ាក់សេ ខេត្តចំប៉ាសាក់ នៃប្រទេសឡាវ នាថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៦
**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣រស.១៦០៨.៧៦៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**ហត្ថលេខា**
**ម៉ៅ ហាវណ្ណាល់**

លេខ: ៧៥៥៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

២/២

# ពិធីសារ

# អនុវត្តកញ្ចប់កិច្ចសន្យាទី ៧ និងទី ៨

# នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

# ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន

# ស្តីពីសេវាកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៤ សជណ.ករ៥

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីព្រាងច្បាប់
# ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម

កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ ដោយឯកឧត្តម ម៉ៅ ហាវណ្ណាល់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាតំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចព្រមព្រៀងនេះ ត្រូវបានបង្កើតឡើងក្នុងគោលដៅ ដូចខាងក្រោម ៖

- ពង្រឹងកិច្ចសហប្រតិបត្តិការ លើផ្នែកសេវាកម្មក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង លើភាពស័ក្តិសិទ្ធិ និងការប្រកួតប្រជែងសមត្ថភាព សមត្ថភាពផលិតកម្ម ប្រព្រឹត្តកម្ម ផ្គត់ផ្គង់ និងការចែកចាយសេវាកម្មរបស់អ្នកផ្គត់ផ្គង់សេវាកម្មក្នុងរង្វង់និងខាងក្រៅតំបន់អាស៊ាន
- លុបបំបាត់ការរឹតត្បិតហួសហេតុ ចំពោះពាណិជ្ជកម្មសេវាកម្ម ក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន
- ធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម តាមរយៈការពង្រីកនូវទំហំ និងស៊ីជម្រៅនៃសេរីភាវូបនីយកម្មលើសពីការអនុវត្តរបស់ប្រទេសជាសមាជិកដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម(GATS) ដើម្បីសម្រេចបាននូវគោលបំណងពាណិជ្ជកម្មដោយសេរីលើផ្នែកសេវាកម្ម។

ដើម្បីសម្រេចគោលដៅខាងលើ បណ្តាប្រទេសជាសមាជិកត្រូវធ្វើការចរចាជាបន្តបន្ទាប់តាមរយៈការផ្តល់ជាពិធីសារអនុវត្តកញ្ចប់កិច្ចសន្យា។ សម្រាប់សេវាកម្មក្នុងផ្នែកដឹកជញ្ជូនតាមផ្លូវអាកាស កញ្ចប់កិច្ចសន្យាចំនួន១៣ប្រភេទត្រូវបានកំណត់ឡើងតាមគោលការណ៍ណែនាំមួយដែលបានអនុម័តដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ មកដល់ពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាបានសន្យា និងផ្តល់សច្ចាប័នរួចហើយនូវពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាចំនួន៦ ដែលរួមមាន ៖

- ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១ ស្តីពីសេវាកម្មជួសជុល និងថែទាំអាកាសយាន
- ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី២ ស្តីពីសេវាកម្មលក់និងម៉ាឃីតធីងនៃការដឹកជញ្ជូនតាមផ្លូវអាកាស
- ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៣ ស្តីពីសេវាកម្មផ្គត់ផ្គង់ព័ត៌មានតាមរយៈប្រព័ន្ធកុំព្យូទ័រ
- ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៤ ស្តីពីសេវាកម្មជួលអាកាសយានមានអាកាសយានិក
- ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៥ ស្តីពីសេវាកម្មជួលអាកាសយានគ្មានអាកាសយានិក
- ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៦ ស្តីពីសេវាកម្មដឹកជញ្ជូនទំនិញបញ្ញើតាមផ្លូវអាកាស។

ក្នុងការចូលរួមចំណែកអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម តាមរយៈការផ្តល់សិទ្ធិប្រទានរបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានចុះហត្ថលេខាលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាចំនួន២ ជាបន្ថែមទៀត រួមមាន ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ ស្តីពីសេវាកម្មបម្រើម្ហូបអាហារនៅលើអាកាសយាន កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា និងពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៨ ស្តីពីសេវាកម្មផ្គត់ផ្គង់ប្រេងឥន្ធនៈអាកាសយាន កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ នៅទីក្រុងប៉ាក់សេ ខេត្តចំប៉ាសាក់ ប្រទេសឡាវ ដែលដាក់ជូនសម្រាប់អនុម័តយល់ព្រមនាពេលនេះ។

ការផ្តល់ការអនុម័តលើកញ្ចប់កិច្ចសន្យាទី៧និងទី៨នេះ នឹងចូលរួមចំណែកយ៉ាងសំខាន់ដល់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម និងផ្តល់ភាពទាក់ទាញបន្ថែមទៀតនៃការវិនិយោគលើផ្នែកសេវាកម្មបម្រើម្ហូបអាហារនៅលើអាកាសយាននិងសេវាកម្មផ្គត់ផ្គង់ប្រេងឥន្ធនៈអាកាសយាន។ ជាលទ្ធផលវិស័យអាកាសចរស៊ីវិលនឹងនាំមកនូវការរីកចម្រើនដ៏រឹងមាំមួយ និងជាចលករយ៉ាងសំខាន់នាំមកនូវភាពរីកចម្រើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

**ខ្លឹមសារនៃពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀង ក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម មានដូចតទៅ ៖**

- ខ្លឹមសារនៃពិធីសារនេះ មានអត្ថន័យដូចខ្លឹមសារនៃពិធីសារមុនៗដែលបានទទួលការអនុម័តនាពេលកន្លងទៅ
- ខ្លឹមសារនៃពិធីសារនេះមានការរំលឹកឡើងវិញនូវការខិតខំប្តេជ្ញាចិត្តរបស់បណ្តាប្រទេសជាសមាជិកអាស៊ាន លើការបើកចំហសេរីផ្នែកពាណិជ្ជកម្មសេវាកម្មនៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស
- ចំពោះពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ ភាគីកម្ពុជាបានផ្តល់ជូនភាគីអាស៊ាននូវការបើកចំហសេរីឬសេរីភាវូបនីយកម្មតាមរយៈការផ្តល់កញ្ចប់កិច្ចសន្យាស្តីពី *សេវាកម្មបម្រើម្ហូបអាហារនៅលើអាកាសយាន* ដោយអនុញ្ញាតផ្តល់ជូនវិនិយោគិនមកពីបណ្តាប្រទេសអាស៊ានធ្វើការវិនិយោគដំណើរការក្រុមហ៊ុនអាជីវកម្មបម្រើម្ហូបអាហារនៅលើអាកាសយាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំមានការរឹតត្បិតណាមួយ និងអនុវត្តតាមច្បាប់វិនិយោគជាធរមានតែប៉ុណ្ណោះ។

- ចំពោះពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៨ ភាគីកម្ពុជាបានផ្តល់ជូនភាគីអាស៊ាននូវការបើកចំហសេរីឬសេរីភាវូបនីយកម្មតាមរយៈការផ្តល់កញ្ចប់កិច្ចសន្យាស្តីពី "*សេវាកម្មផ្គត់ផ្គង់ប្រេងឥន្ធនៈអាកាសយាន*" ដោយអនុញ្ញាតផ្តល់ជូនវិនិយោគិនមកពីបណ្តាប្រទេសអាស៊ានធ្វើការវិនិយោគដំណើរការក្រុមហ៊ុនអាជីវកម្មផ្គត់ផ្គង់ប្រេងឥន្ធនៈអាកាសយាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំមានការរឹតត្បិតណាមួយ និងអនុវត្តតាមច្បាប់វិនិយោគជាធរមានតែប៉ុណ្ណោះ។

សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ ដើម្បីបញ្ជូនទៅសុំការពិនិត្យ និងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ដែលរួមមាន២មាត្រា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម ដោយក្តីអនុគ្រោះ។ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# សេចក្តីព្រាង
# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម

**មាត្រា១.-**

អនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ និងពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៨ នៅទីក្រុងប៉ាក់សេ ខេត្តចំប៉ាសាក់ នៃប្រទេសឡាវ នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តពល់នីតិវិធី ដើម្បីអនុវត្តពិធីសារនេះ។៚

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០១៦
នាសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៥។
រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ២០១៦

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

# ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧

# នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

# ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន

# ស្តីពីសេវាកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៧៥ សប្រទ.

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១១*

# សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## រាជរដ្ឋាភិបាល

ប្រទានសិទ្ធិពេញសមត្ថភាពជូន ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីចុះហត្ថលេខាលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ ស្តីពីសេវាកម្មបំរើម្ហូបអាហារលើអាកាសយាននៃសេវាកម្មដឹកជញ្ជូនផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម នៅកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី១៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១២ ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើលិខិតសិទ្ធិប្រទាននេះ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

រាជរដ្ឋាភិបាល
*Royal Government*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

No: 175 D.F.P

Phnom Penh, December 13 2011

## DELEGATION OF FULL POWERS

- Considering the Constitution of the Kingdom of Cambodia,
- Considering the Royal Degree NS/RKT/0908/1055 dated 25 September 2008 on the nomination of the Royal Government of the Kingdom of Cambodia,
- Considering the Royal Kram 02/NS/94 dated 20 July 1994 promulgating the Law on the Organization and Functioning of the Council of Ministers,
- Considering the Royal Kram NS/RKM/0196/09 dated 24 January 1996 on the establishment of the Office of the Council of Ministers,
- Considering the Royal Kram NS/RKM/0196/23 dated 24 January 1996 promulgated the Law on the establishment of the State Secretariat of Civil Aviation,
- Pursuant to the Proposal of the Secretary of State of the State Secretariat of Civil Aviation,

## THE ROYAL GOVERNMENT

Delegates herewith Full Powers to **H.E. Mr. Mao Havannall**, Secretary of State, the State Secretariat of Civil Aviation, to sign the Protocol to Implement the Seven Package of Commitments on Aircraft Catering Services of the Air Transport Services Under the ASEAN Framework Agreement on Services at the 17th ASEAN Transport Minister Meeting which will be held from 12 to 16 December 2011 in Phnom Penh, the Kingdom of Cambodia.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed this Delegation of Full Powers.

Prime Minister

Samdech Akka Moha Sena Padei Techo **HUN SEN**

# ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម

រដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ តទៅនេះហៅកាត់ជារួមថា **អាស៊ាន** ឬ**បណ្តារដ្ឋសមាជិក** ឬហៅកាត់ដោយឡែកថា **រដ្ឋសមាជិក**

យោងលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ ដែលមានបំណងជំរុញឲ្យមានការលើកកម្ពស់កិច្ចសហប្រតិបត្តិការសេវាកម្ម ក្នុងចំណោមបណ្តារដ្ឋសមាជិក លុបបំបាត់នូវការរឹតត្បិតការធ្វើពាណិជ្ជកម្មសេវាកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក និងធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម ដោយធ្វើការពង្រីកឲ្យកាន់តែស៊ីជម្រៅ និងវិសាលភាពសេរីភាវូបនីយកម្មឲ្យលើសពីសេរីភាវូបនីយកម្មសេវាកម្ម ដែលបានអនុវត្តដោយបណ្តារដ្ឋសមាជិក ក្រោមកិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្មសេវាកម្ម ដែលតទៅនេះត្រូវបានហៅកាត់ថា GATS របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលតទៅនេះ ត្រូវបានហៅកាត់ថា WTO។

ដោយបានធ្វើការចរចាចំនួនប្រាំ(៥)លើក និងសម្រេចបាននូវតារាងកម្មវិធីការសន្យាជាក់លាក់ចំនួនប្រាំមួយ(៦) ដែលមានកំណត់នៅក្នុងពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី២ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៣ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៤ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៥ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ និងពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៦ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម។

យោងលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន សម្រាប់សមាហរណកម្មលើវិស័យអាទិភាព រួមគ្នាជាមួយនឹងផែនទីបង្ហាញផ្លូវសម្រាប់សមាហរណកម្មលើវិស័យអាទិភាព បានចុះហត្ថលេខាដោយថ្នាក់ដឹកនាំអាស៊ាន នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅរដ្ឋធានីវៀងចន្ទន៍ ប្រទេសឡាវ និងកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន (ស្តីពីវិសោធនកម្ម) សម្រាប់សមាហរណកម្មលើវិស័យអាទិភាព បានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៦ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ដែលរួមបញ្ចូលវិស័យដឹកជញ្ជូនតាមផ្លូវអាកាស ដាក់ចេញនូវវិធានការសម្រាប់ធ្វើឲ្យកាន់តែប្រសើរឡើង និងពង្រីកវិសាលភាពសមាហរណកម្ម និងទំនាក់ទំនងសេដ្ឋកិច្ចផ្ទៃក្នុង ដោយមានការចូលរួមពីវិស័យឯកជន ដើម្បីសម្រេចឲ្យបាននូវសហគមសេដ្ឋកិច្ចអាស៊ានមួយ។

ដោយយកចិត្តទុកដាក់ទៅលើគោលដៅ និងរយៈពេលកំណត់នៃផែនការលម្អិតសហគមសេដ្ឋកិច្ចអាស៊ាន ដែលបានអនុម័តឡើង នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១៣ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅប្រទេសសិង្ហបុរី ដែលត្រៀមសម្រាប់ការជ្រោមជ្រែងលើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មតាមរយៈការធ្វើសេរីភាវូបនីយកម្មក្នុងដំណាក់កាលជាបន្តបន្ទាប់ ដែលនឹងបញ្ចប់នៅឆ្នាំ២០១៥។

ដោយបានអនុវត្តនូវការចរចាជាបន្តបន្ទាប់ដោយអនុលោមតាមមាត្រា៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម និងបានបញ្ចប់ដោយស្ថាពរនូវកញ្ចប់កិច្ចសន្យាទី៧។

ដោយមានបំណងប្រកាសនៅក្នុងតារាងកម្មវិធីនូវការសន្យាជាក់លាក់ ដែលរដ្ឋសមាជិកនីមួយៗត្រូវអនុវត្ត ដែលបង្កើតឡើងក្នុងគោលបំណងផ្តល់ការអនុញ្ញាត នូវប្រព្រឹត្តកម្មអនុគ្រោះទៅឲ្យរដ្ឋសមាជិកមួយផ្សេងទៀត ដោយផ្អែកលើមូលដ្ឋានប្រទេសដែលទទួលបានការអនុគ្រោះបំផុត។

បានព្រមព្រៀងគ្នា ដូចខាងក្រោម ៖

១. បណ្តារដ្ឋសមាជិកដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ត្រូវបន្តពង្រីកការសន្យាជាក់លាក់របស់ខ្លួន ក្រោមកិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ទៅដល់រដ្ឋសមាជិកអាស៊ានដែលមិនមែនជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក។

២. រដ្ឋសមាជិកនីមួយៗ ត្រូវពង្រីកនូវប្រព្រឹត្តកម្មអនុគ្រោះទាក់ទងទៅនឹងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ដល់រដ្ឋសមាជិកដទៃផ្សេងទៀត ដូចមានចែងនៅក្នុងតារាងកម្មវិធីនូវការសន្យាជាក់លាក់ ដែលមាននៅក្នុងឧបសម្ព័ន្ធនៃពិធីសារនេះ។

៣. ឧបសម្ព័ន្ធនៃពិធីសារនេះ គឺជាតារាងកម្មវិធីរួមបញ្ចូលគ្នាមួយនូវការសន្យាជាក់លាក់ ថាត្រូវអនុវត្តរបស់រដ្ឋសមាជិកនីមួយៗ ដែលបង្កើតបានជាផ្នែកសំខាន់នៃពិធីសារនេះ។

៤. ពិធីសារនេះ និងឧបសម្ព័ន្ធរបស់ពិធីសារនេះ ត្រូវបង្កើតបានជាផ្នែកសំខាន់រួមមួយ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។

៥. ពិធីសារនេះ ត្រូវចូលជាធរមាននៅថ្ងៃទីហុកសិប(៦០) បន្ទាប់ពីការតម្កល់លិខិតុបករណ៍ នៃការផ្តល់សច្ចាប័ន ឬលិខិតទទួលស្គាល់ទីប្រាំមួយ(៦) ពីបណ្តារដ្ឋសមាជិកអាស៊ាន និងអគ្គលេខាធិការដ្ឋានអាស៊ាន ហើយពិធីសារនេះនឹងមានប្រសិទ្ធភាព ចំពោះបណ្តារដ្ឋសមាជិកដែលបានផ្តល់សច្ចាប័ន ឬទទួលស្គាល់ពិធីសារនេះតែប៉ុណ្ណោះ។ ចំពោះរដ្ឋសមាជិកនីមួយៗ ដែលបានផ្តល់សច្ចាប័ន ឬទទួលស្គាល់ពិធីសារនេះ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍ នៃការផ្តល់សច្ចាប័ន ឬនៃការទទួលស្គាល់ទីប្រាំមួយ(៦) ពិធីសារត្រូវចូលជាធរមាននៅថ្ងៃទីហុកសិប(៦០) បន្ទាប់ពីការតម្កល់ទុកដោយរដ្ឋសមាជិកនេះ នូវលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការទទួលស្គាល់។

៦. ពិធីសារនេះ ត្រូវបានតម្រូវឲ្យតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកត្រូវផ្តល់ឯកសារច្បាប់ចម្លងផ្លូវការនៃពិធីសារនេះ ជូនទៅរដ្ឋសមាជិកនីមួយៗ។ អគ្គលេខាធិការដ្ឋានអាស៊ាន ត្រូវធ្វើការជូនដំណឹងទៅរដ្ឋភាគីនីមួយៗផងដែរ ស្តីពីការផ្តល់សច្ចាប័ន ឬការទទួលស្គាល់ ដែលបានបង្កើតឡើងដោយអនុលោមតាមកថាខណ្ឌទី៥។

ដើម្បីជាសក្ខីភាព ហត្ថលេខីដែលបានទទួលសិទ្ធិអនុញ្ញាតស្របច្បាប់សម្រាប់ការចុះហត្ថលេខាពីរដ្ឋាភិបាលរបស់ពួកគេរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារសម្រាប់អនុវត្តកញ្ចប់កិច្ចសន្យាទី៧ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ ជាអត្ថបទភាសាអង់គ្លេស ច្បាប់ដើមចំនួនមួយច្បាប់។

**រដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម**

..................................................................

**ប៉េហីន ដាតូ អាប៊ូ បាកា អាប៉ុង**
រដ្ឋមន្ត្រី ក្រសួងគមនាគមន៍

**រាជរដ្ឋាភិបាលនៃកម្ពុជា**

..................................................................

**ម៉ៅ ហាវណ្ណាល់**
រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

**រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី**

..................................................................

**អ៊ី អ៊ី ម៉ានហ្គីនដារអាន**
រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

..................................................................

**សុំម៉ាដ ផូលសេនា**
រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

**រដ្ឋាភិបាលនៃម៉ាឡេស៊ី**

..................................................................

**ដាតូ សេរី គង់ ចូ ហា**
រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា**

..................................................................

**យូ នីយ៉ាន ធុន អ៊ូង**
រដ្ឋមន្ត្រីសហភាព ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន**

..................................................................

**អេហ្វ្រិន ស៊ី. មុនតូប៉ា**
អនុរដ្ឋមន្ត្រី សម្រាប់ការអនុវត្តន៍គម្រោង និងបញ្ហាប្រឈមពិសេស
នៃក្រសួងដឹកជញ្ជូន និងគមនាគមន៍ នៃប្រទេសហ្វីលីពីន

**រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី**

..........................................................

**ឡួយ ធុក យេវ**
រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ**

..........................................................

**នាយឧត្តមសេនីយ៍ឯកនគរបាល ឆាត់ គុលឌីឡុកេ**
អនុរដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

..........................................................

**ឌិញ ឡា ថាង**
រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**តារាងកម្មវិធីនៃការសន្យាជាក់លាក់ របស់ព្រះរាជាណាចក្រកម្ពុជា**

**ប្រភេទផ្គត់ផ្គង់:** ១) ការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់សេវាកម្មក្រៅប្រទេស ៣) រូបវន្តបុគ្គល ៤) ចលនានៃកំលាំងពលកម្ម

| **វិស័យ ឬអនុវិស័យ** | **ការកម្រិតច្រកទីផ្សារ** | **ការកម្រិតនៃប្រព្រឹត្តកម្មជាតិ** | **ការសន្យាបន្ថែម** |
|---|---|---|---|
| **សេវាកម្មបម្រើម្ហូបអាហារនៅលើអាកាសយាន** | ១) បើកចំហរ<br>២) បើកចំហរ<br>៣) បើកចំហរ ផ្អែកទៅលើច្បាប់ទូទៅ<br>៤) ដូចមានបញ្ជាក់នៅក្នុងច្បាប់ទូទៅ | ១) បើកចំហរ<br>២) បើកចំហរ<br>៣) ដូចមានបញ្ជាក់នៅក្នុងច្បាប់ទូទៅ<br>៤) ដូចមានបញ្ជាក់នៅក្នុងច្បាប់ទូទៅ | |

# PROTOCOL TO IMPLEMENT THE SEVENTH PACKAGE OF COMMITMENTS ON AIR TRANSPORT SERVICES UNDER THE ASEAN FRAMEWORK AGREEMENT ON SERVICES

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, Lao People's Democratic Republic (Lao PDR), Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member States of the Association of South East Asian Nations (hereinafter collectively referred to as "ASEAN" or "Member States" or singularly "Member State");

**NOTING** the ASEAN Framework Agreement on Services signed on 15 December 1995 in Bangkok, Thailand, which seeks to enhance cooperation in services amongst Member States, eliminate substantially restrictions to trade in services amongst Member States and liberalise trade in services by expanding the depth and scope of liberalisation beyond those undertaken by Member States under the General Agreement on Trade in Services (hereinafter referred to as "GATS") of the World Trade Organisation (hereinafter referred to as "WTO");

**HAVING** carried out five rounds of negotiations and concluded six sets of schedule of specific commitments embodied in the Protocol to Implement the Initial Package of Commitments under the ASEAN Framework Agreement on Services signed on 15 December 1997 in Kuala Lumpur, Malaysia; the Protocol to Implement the Second Package of Commitments under the ASEAN Framework Agreement on

Services signed on 16 December 1998 in Ha Noi, Viet Nam; the Protocol to Implement the Third Package of Commitments under the ASEAN Framework Agreement on Services signed on 31 December 2001; the Protocol to Implement the Fourth Package of Commitments under the ASEAN Framework Agreement on Services signed on 23 November 2004 in Phnom Penh, Cambodia; the Protocol to Implement the Fifth Package of Commitments under the ASEAN Framework Agreement on Services signed on 8 February 2007 in Bangkok, Thailand; and the Protocol to Implement the Sixth Package of Commitments under the ASEAN Framework Agreement on Services signed on 10 December 2009 in Ha Noi, Viet Nam;

**NOTING** the ASEAN Framework Agreement for the Integration of Priority Sectors together with the Roadmap for the Integration of Priority Sectors signed by the ASEAN Leaders on 29 November 2004 in Vientiane, Lao PDR, and the ASEAN Framework (Amendment) Agreement for the Integration of Priority Sectors signed by the ASEAN Economic Ministers on 8 December 2006 in Cebu, Philippines, which includes Air Transport, provide measures to deepen and broaden internal economic integration and linkages, with the participation of the private sector, to realise an ASEAN Economic Community.

**MINDFUL** of the targets and timelines of the ASEAN Economic Community Blueprint adopted at the 13$^{th}$ ASEAN Summit held on 21 November 2007 in Singapore that, amongst others, provided for the liberalisation of trade in services through consecutive rounds of liberalisation ending in 2015;

**HAVING** carried out subsequent negotiations pursuant to Article IV of the ASEAN Framework Agreement on Services and finalised the seventh package of commitments;

**DESIRING** to set out in a schedule, the specific commitments that each Member State shall undertake, for

which Member States shall accord preferential treatment to one another on a Most-Favoured Nations basis:

**HAVE AGREED AS FOLLOWS:**

1. Member States who are WTO Members shall continue to extend their specific commitments under GATS to ASEAN Member States who are non-WTO Members.

2. Each Member State shall extend to all other Member States preferential treatment in air transport services as set forth in the Schedules of Specific Commitments annexed to this Protocol.

3. The Annex to this Protocol is the consolidated schedules of each Member State's specific commitments which shall form an integral part of this Protocol.

4. This Protocol and its Annex shall form an integral part of the ASEAN Framework Agreement on Services.

5. This Protocol shall enter into force on the sixtieth day after the deposit of the sixth Instrument of Ratification or Acceptance from ASEAN Member States with the Secretary-General of ASEAN, and shall become effective only among the Member States that have ratified or accepted it. For each Member State ratifying or accepting the Protocol after the deposit of the sixth Instrument of Ratification or Acceptance, the Protocol shall enter into force on the sixtieth day after the deposit by such Member State of its Instrument of Ratification or Acceptance.

6. This Protocol shall be deposited with the Secretary-General of ASEAN who shall promptly furnish a certified copy thereof to each Member State. The Secretary-General of ASEAN shall also promptly furnish notifications of ratifications or acceptances made pursuant to paragraph 5 to each Member State.

**IN WITNESS WHEREOF**, the undersigned, being duly authorised thereto by their respective Governments, have signed the Protocol to Implement the Seventh Package of Commitments on Air Transport Services under the ASEAN Framework Agreement on Services.

**DONE** at **Phnom** Penh, **Cambodia** this **Sixteenth** Day of **December** in the Year Two **Thousand and Eleven**, in a single original copy in the English Language.

For the Government of Brunei Darussalam:

................................
**PEHIN DATO ABDULLAH BAKAR**
Minister of Communications

For the Royal Government of Cambodia:

................................
**MAO HAVANNALL**
Secretary of State
State Secretariat of Civil Aviation

For the Government of the Republic of Indonesia:

.......................................

**E. E. MANGINDAAN**
Minister for Transportation

For the Government of the Lao People's Democratic Republic:

.......................................

**SOMMAD PHOLSENA**
Minister of Public Works and Transport

For the Government of Malaysia:

.......................................

**DATO' SERI KONG CHO HA**
Minister of Transport

For the Government of the Republic of the Union of Myanmar:

……………………………
**U NYAN HTUN AUNG**
Union Minister for Transport

For the Government of the Republic of the Philippines:

……………………………
**EFREN C. MONCUPA**
Undersecretary for Project Implementation and Special Concerns
Department of Transportation and Communications of the Philippines

For the Government of the Republic of Singapore:

……………………………
**LUI TUCK YEW**
Minister for Transport

For the Government of the Kingdom of Thailand:

.....................................

**POLICE LIEUTENANT GENERAL CHATT KULDILOKE**
Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam:

.....................................

**DINH LA THANG**
Minister of Transport

## CAMBODIA – SCHEDULE OF SPECIFIC COMMITMENTS

Mode of Supply: 1) Cross-border 2) Consumption abroad 3) Commercial Presence 4) Presence of natural persons

| Sector or Sub-Sector | Limitation on Market Access | Limitation on National Treatment | Additional Commitments |
|---|---|---|---|
| **Aircraft Catering Services** | 1) None<br>2) None<br>3) None other than that indicated in the horizontal section<br>4) As indicated in the horizontal section | 1) None<br>2) None<br>3) As indicated in the horizontal section<br>4) As indicated in the horizontal section | |

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SCRETARIAT asean

# ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៨

# នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

# ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន

# ស្តីពីសេវាកម្ម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៨៩ សសរ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៣

## សិទ្ធិប្រទាន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

-តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## រាជរដ្ឋាភិបាល

ប្រទានសិទ្ធិជូន ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីចុះហត្ថលេខាពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមសិទ្ធិប្រទាននេះ។

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

រាជរដ្ឋាភិបាល
*Royal Government*

N° 79 D.F.P

Phnom Penh, November 20, 2013

## DELEGATION OF FULL POWERS

Considering the Constitution of the Kingdom of Cambodia,
Considering the Royal Degree NS/RKT/0913/903 dated 24 September 2013 on the nomination of the Royal Government of the Kingdom of Cambodia,
Considering the Royal Kram 02/NS/94 dated 20 July 1994 promulgating the Law on the Organization and Functioning of the Council of Ministers,
Considering the Royal Kram NS/RKM/0196/23 dated 24 January 1996 promulgated the Law on the establishment of the State Secretariat of Civil Aviation,
Pursuant to the Proposal of the Secretary of State of the State Secretariat of Civil Aviation.

## THE ROYAL GOVERNMENT

Delegates herewith Full Powers to **H.E. Mr. Mao Havannall**, Secretary of State, the State Secretariat of Civil Aviation, to sign the Protocol to Implement the Eighth Package of Commitments on Air Transport Services Under the ASEAN Framework Agreement on Services.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed this Delegation of Full Powers.

**Prime Minister**

Samdech Akka Moha Sena Padei Techo **HUN SEN**

## ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម

រដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ តទៅនេះហៅកាត់ជារួមថា **អាស៊ាន** ឬ**បណ្តារដ្ឋសមាជិក** ឬហៅកាត់ដោយឡែកថា **រដ្ឋសមាជិក**

យោងលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ ដែលមានបំណងជំរុញឲ្យមានការលើកកម្ពស់កិច្ចសហប្រតិបត្តិការសេវាកម្ម ក្នុងចំណោមបណ្តារដ្ឋសមាជិក លុបបំបាត់នូវការរឹតត្បិតការធ្វើពាណិជ្ជកម្មសេវាកម្ម ក្នុងចំណោមបណ្តារដ្ឋសមាជិក និងធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មដោយធ្វើការពង្រីកឲ្យកាន់តែស៊ីជម្រៅ និងវិសាលភាពសេរីភាវូបនីយកម្ម ឲ្យលើសពីសេរីភាវូបនីយកម្មនៃសេវាកម្មដែលបានអនុវត្តដោយបណ្តារដ្ឋសមាជិក ក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ដែលតទៅនេះ ត្រូវបានហៅកាត់ថា GATS របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលតទៅនេះ ត្រូវបានហៅកាត់ថា WTO។

ដោយបានធ្វើការចរចាចំនួនប្រាំមួយ(៦)លើក និងសម្រេចបាននូវតារាងកម្មវិធី ស្តីពីការសន្យាជាក់លាក់ចំនួនប្រាំពីរ(៧) ដែលមានកំណត់នៅក្នុងពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ នៅរដ្ឋធានីគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី២ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៣ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៤ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៥ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៦ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បានចុះហត្ថលេខានៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម និងពិធីស[illegible] កញ្ចប់កិច្ចសន្យាទី៧ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម បាន[illegible]

ហត្ថលេខានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

យោងលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានសម្រាប់សមាហរណកម្មលើវិស័យអាទិភាពរួមគ្នាជាមួយនឹងផែនទីបង្ហាញផ្លូវសម្រាប់សមាហរណកម្មលើវិស័យអាទិភាព បានចុះហត្ថលេខាដោយថ្នាក់ដឹកនាំអាស៊ាន នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅរដ្ឋធានីវៀងចន្ទន៍ ប្រទេសឡាវ និងកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន (ស្តីពីវិសោធនកម្ម) សម្រាប់សមាហរណកម្មលើវិស័យអាទិភាព បានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៦ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ដែលរួមបញ្ចូលវិស័យដឹកជញ្ជូនតាមផ្លូវអាកាស ដាក់ចេញនូវវិធានការសម្រាប់ធ្វើឲ្យកាន់តែប្រសើរឡើង និងពង្រីកវិសាលភាពនៃសមាហរណកម្ម និងទំនាក់ទំនងសេដ្ឋកិច្ចផ្ទៃក្នុង ដោយមានការចូលរួមពីវិស័យឯកជន ដើម្បីសម្រេចឲ្យបាននូវសហគមសេដ្ឋកិច្ចអាស៊ានមួយ។

យោងលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីចលនានៃរូបវន្តបុគ្គល បានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅក្នុងអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ាន កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលនឹងជួយសម្រួលដល់ចលនារបស់ប្រជាជនអាស៊ាន ក្នុងការចូលរួមធ្វើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម និងការវិនិយោគក្នុងតំបន់ និងកិច្ចព្រមព្រៀងណាមួយ ដែលនៅពេលចូលជាធរមានឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀងនោះ អាចនឹងប្រើប្រាស់ជំនួសកិច្ចសន្យាដែលត្រូវបានបង្កើតឡើង ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម ដោយមានទំនាក់ទំនងទៅនឹងទម្រង់ទី៤ (ចលនារបស់រូបវន្តបុគ្គល)។

ដោយយកចិត្តទុកដាក់ទៅលើគោលដៅ និងរយៈពេលកំណត់នៃផែនការលម្អិតរបស់សហគមសេដ្ឋកិច្ចអាស៊ាន ដែលបានអនុម័តឡើងនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១៣ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅប្រទេសសិង្ហបុរី ដែលត្រៀមសម្រាប់ការជ្រោមជ្រែងលើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម ចំពោះប្រទេស និងប្រទេស តាមរយៈការធ្វើសេរីភាវូបនីយកម្មក្នុងដំណាក់កាលជាបន្តបន្ទាប់ ដែលនឹងត្រូវបញ្ចប់នៅឆ្នាំ២០១៥។

ដោយបានអនុវត្តឡើងនូវការចរចាជាបន្តបន្ទាប់ដោយអនុលោមតាមមាត្រា៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម និងបានបញ្ចប់ដោយស្ថាពរនូវ[illegible] កិច្ចសន្យាទី៨។

ដោយមានបំណងប្រកាសក្នុងតារាងកម្មវិធីនូវការសន្យាជាក់លាក់ ដែលរដ្ឋសមាជិកនីមួយៗត្រូវអនុវត្ត បង្កើតឡើងក្នុងគោលបំណងផ្តល់ការអនុញ្ញាតនូវប្រព្រឹត្តកម្មអនុគ្រោះ ដល់រដ្ឋសមាជិកមួយផ្សេងទៀត ដោយផ្អែកលើមូលដ្ឋាន ប្រទេសដែលទទួលបានការអនុគ្រោះបំផុត។

បានព្រមព្រៀងគ្នា ដូចខាងក្រោម៖

១. រដ្ឋសមាជិកនីមួយៗ ត្រូវពង្រីកនូវប្រព្រឹត្តកម្មអនុគ្រោះទាក់ទងទៅនឹងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសដល់រដ្ឋសមាជិកដទៃផ្សេងទៀតទាំងអស់ ដូចមានចែងនៅក្នុងតារាងកម្មវិធីនូវការសន្យាជាក់លាក់ ដែលមាននៅក្នុងឧបសម្ព័ន្ធនៃពិធីសារនេះ។

២. ឧបសម្ព័ន្ធនៃពិធីសារនេះ គឺជាតារាងកម្មវិធីរួមបញ្ចូលគ្នាមួយនូវការសន្យាជាក់លាក់ ថាត្រូវអនុវត្តរបស់រដ្ឋសមាជិកនីមួយៗ ដែលត្រូវបង្កើតបានជាផ្នែកសំខាន់នៃពិធីសារនេះ។

៣. ពិធីសារនេះ និងឧបសម្ព័ន្ធរបស់ពិធីសារនេះ ត្រូវបង្កើតបានជាផ្នែកសំខាន់រួមមួយ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។

៤. ពិធីសារនេះ ត្រូវចូលជាធរមាននៅថ្ងៃទីហុកសិប(៦០) បន្ទាប់ពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬលិខិតទទួលស្គាល់ទីប្រាំពីរ(៧) ពីបណ្តារដ្ឋសមាជិកអាស៊ាន និងអគ្គលេខាធិការដ្ឋានអាស៊ាន ហើយពិធីសារនេះនឹងមានប្រសិទ្ធភាពតែចំពោះបណ្តារដ្ឋសមាជិក ដែលបានផ្តល់សច្ចាប័ន ឬទទួលស្គាល់ពិធីសារនេះតែប៉ុណ្ណោះ។ ចំពោះរដ្ឋសមាជិកនីមួយៗ ដែលបានផ្តល់សច្ចាប័ន ឬទទួលស្គាល់ពិធីសារនេះ ក្រោយពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬនៃការទទួលស្គាល់ទីប្រាំពីរ(៧) ពិធីសារនឹងត្រូវចូលជាធរមាននៅថ្ងៃទីហុកសិប(៦០) បន្ទាប់ពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬនៃការទទួលស្គាល់ដោយរដ្ឋសមាជិកនេះ។

៥. ពិធីសារនេះ ត្រូវបានតម្រូវឲ្យតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកត្រូវផ្តល់ឯកសារច្បាប់ចម្លងផ្លូវការនៃពិធីសារនេះ ជូនទៅកាន់រដ្ឋសមាជិកនីមួយៗ។ អគ្គលេខាធិការដ្ឋានអាស៊ាន ត្រូវធ្វើការជូនដំណឹងទៅកាន់រដ្ឋភាគីនីមួយៗផងដែរ ស្តីពីការផ្តល់សច្ចាប័ន ឬការទទួលស្គាល់ ដែលបានធ្វើឡើងដោយអនុលោមតាមកថាខណ្ឌទី៥។

ដើម្បីជាសក្ខីភាព ហត្ថលេខីដែលបានទទួលសិទ្ធិអនុញ្ញាតស្របច្បាប់សម្រាប់ការចុះហត្ថលេខាពីរដ្ឋាភិបាលរបស់ពួកគេរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។

ធ្វើនៅទីក្រុងប៉ាក់សេ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ជាអត្ថបទភាសាអង់គ្លេស ច្បាប់ដើមចំនួនមួយច្បាប់។

**រដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម**

..............................................

**ប៉េហ៊ីន ដាតូ អាប់ឌុលឡា បាកា**

រដ្ឋមន្ត្រី ក្រសួងគមនាគមន៍

**រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

..............................................

**ម៉ៅ ហាវណ្ណាល់**

រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

**រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី**

..............................................

**អ៊ី អ៊ី ម៉ានហ្គី**

**នដាអាន**

រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

..............................................

**សុំម៉ាដ ផូលសេនា**

រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

**រដ្ឋាភិបាលនៃម៉ាឡេស៊ី**

..............................................

**ដាទុក អេប អាស៊ីស ប៊ីន ភាប្រាឌី**

អនុរដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា**

..............................................................

**នីយ៉ាន ធុន អ៊ូង**
រដ្ឋមន្ត្រីសហភាព ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន**

..............................................................

**អាតទី ខេធីរីន ចេននីហ្វ័រ តី. ហ្គានសាឡេស៍**
រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន និងគមនាគមន៍

**រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី**

..............................................................

**ឡូយ ធុក យេង**
រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ**

..............................................................

**នាយឧត្តមសេនីយ៍កងទ័ពជើងអាកាស ប្រាជីន ជុន តុង**
រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

..............................................................

**ឌិញ ឡា ថាង**
រដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

**តារាងកម្មវិធីនៃការសន្យាជាក់លាក់ របស់ព្រះរាជាណាចក្រកម្ពុជា**

**ប្រភេទផ្គត់ផ្គង់:** ១) ការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែន ២) ការប្រើប្រាស់សេវាកម្មក្រៅប្រទេស ៣) រូបវន្តបុគ្គល

| វិស័យ ឬអនុវិស័យ | ការកម្រិតច្រកចូលទីផ្សារ | ការកម្រិតនៃប្រព្រឹត្តកម្មជាតិ | ការសន្យាបន្ថែម |
|---|---|---|---|
| **សេវាកម្មផ្គត់ផ្គង់ប្រេងឥន្ធនៈ** | ១) បើកចំហរ<br>២) បើកចំហរ<br>៣) បើកចំហរ ផ្អែកទៅលើច្បាប់ទូទៅ | ១) បើកចំហរ<br>២) បើកចំហរ<br>៣) ដូចមានបញ្ជាក់នៅក្នុងច្បាប់ទូទៅ | |

# PROTOCOL TO IMPLEMENT THE EIGHTH PACKAGE OF COMMITMENTS ON AIR TRANSPORT SERVICES UNDER THE ASEAN FRAMEWORK AGREEMENT ON SERVICES

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, Lao People's Democratic Republic (Lao PDR), Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member States of the Association of South East Asian Nations (hereinafter collectively referred to as "ASEAN" or "Member States" or singularly "Member State");

**NOTING** the ASEAN Framework Agreement on Services signed on 15 December 1995 in Bangkok, Thailand, which seeks to enhance cooperation in services amongst Member States, eliminate substantially restrictions to trade in services amongst Member States and liberalise trade in services by expanding the depth and scope of liberalisation beyond those undertaken by Member States under the General Agreement on Trade in Services (hereinafter referred to as "GATS") of the World Trade Organisation (hereinafter referred to as "WTO");

**HAVING** carried out six rounds of negotiations and concluded seven sets of schedule of specific commitments embodied in the Protocol to Implement the Initial Package of Commitments under the ASEAN Framework Agreement on Services signed on 15 December 1997 in Kuala Lumpur, Malaysia; the Protocol to Implement the Second Package of Commitments under the ASEAN Framework Agreement on Services signed on 16 December 1998 in Ha Noi, Viet Nam;

the Protocol to Implement the Third Package of Commitments under the ASEAN Framework Agreement on Services signed on 31 December 2001; the Protocol to Implement the Fourth Package of Commitments under the ASEAN Framework Agreement on Services signed on 23 November 2004 in Phnom Penh, Cambodia; the Protocol to Implement the Fifth Package of Commitments under the ASEAN Framework Agreement on Services signed on 8 February 2007 in Bangkok, Thailand; the Protocol to Implement the Sixth Package of Commitments under the ASEAN Framework Agreement on Services signed on 10 December 2009 in Ha Noi, Viet Nam; and the Protocol to Implement the Seventh Package of Commitments under the ASEAN Framework Agreement on Services signed on 16 December 2011 in Phnom Penh, Cambodia

**NOTING** the ASEAN Framework Agreement for the Integration of Priority Sectors together with the Roadmap for the Integration of Priority Sectors signed by the ASEAN Leaders on 29 November 2004 in Vientiane, Lao PDR, and the ASEAN Framework (Amendment) Agreement for the Integration of Priority Sectors signed by the ASEAN Economic Ministers on 8 December 2006 in Cebu, Philippines, which includes Air Transport, provide measures to deepen and broaden internal economic integration and linkages, with the participation of the private sector, to realise an ASEAN Economic Community

**NOTING** the ASEAN Agreement on the Movement of Natural Persons signed by the ASEAN Economic Ministers during the 21st ASEAN Summit on 19 November 2012 in Phnom Penh, Cambodia that will facilitate the movement of ASEAN people in engaging in trade in goods, trade in services and investment in the region and that upon its entry into force, its Annex 1 shall supersede commitments made under the AFAS in relation to mode 4 (Movement of Natural Persons)

**MINDFUL** of the targets and timelines of the ASEAN Economic Community Blueprint adopted at the 13th ASEAN



CERTIFIED COPY DEPUTY SECRETARY-GENERAL, THE ASEAN SECRETARIAT asean

Summit held on 21 November 2007 in Singapore that, amongst others, provided for the liberalisation of trade in services through consecutive rounds of liberalisation ending in 2015;

**HAVING** carried out subsequent negotiations pursuant to Article IV of the ASEAN Framework Agreement on Services and finalised the eighth package of commitments;

**DESIRING** to set out in a schedule the specific commitments that each Member State shall undertake, for which Member States shall accord preferential treatment to one another on a Most-Favoured Nations basis,

**HAVE AGREED AS FOLLOWS:**

1. Each Member State shall extend to all other Member States preferential treatment in air transport services as set forth in the Schedules of Specific Commitments annexed to this Protocol.

2. The Annex to this Protocol is the consolidated schedules of each Member State's specific commitments which shall form an integral part of this Protocol.

3. This Protocol and its Annex shall form an integral part of the ASEAN Framework Agreement on Services.

4. This Protocol shall enter into force on the sixtieth day after the deposit of the seventh Instrument of Ratification or Acceptance from ASEAN Member States with the Secretary-General of ASEAN, and shall become effective only among the Member States that have ratified or accepted it. For each Member State ratifying or accepting the Protocol after the deposit of the seventh Instrument of Ratification or Acceptance, the Protocol shall enter into force on the sixtieth



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

day after the deposit by such Member State of its Instrument of Ratification or Acceptance.

5. This Protocol shall be deposited with the Secretary-General of ASEAN who shall promptly furnish a certified copy thereof to each Member State. The Secretary-General of ASEAN shall also promptly furnish notifications of ratifications or acceptances made pursuant to paragraph 5 to each Member State.

**IN WITNESS WHEREOF**, the undersigned, being duly authorised thereto by their respective Governments, have signed the Protocol to Implement the Eighth Package of Commitments on Air Transport Services under the ASEAN Framework Agreement on Services.

**DONE** at **Pakse, Lao PDR**, this **Twentieth** Day of **December** in the Year **Two Thousand and Thirteen**, in a single original copy in the English Language.

For the Government of Brunei Darussalam:

**PEHIN DATO ABDULLAH BAKAR**
Minister of Communications

For the the Government of Kingdom of Cambodia:

**MAO HAVANNALL**
Secretary of State
State Secretariat of Civil Aviation

CERTIFIED COPY
DEPUTY SECRETARY-GENERAL, THE ASEAN SECRETARIAT

For the Government of the Republic of Indonesia:

..............................

**E.E. MANGINDAAN**
Minister of Transport

For the Government of the Lao People's Democratic Republic:

..............................

**SOMMAD PHOLSENA**
Minister of Public Works and Transport

For the Government of Malaysia:

..............................

**DATUK AB AZIZ BIN KAPRAWI**
Deputy Minister of Transport

For the Government of the Republic of the Union of Myanmar:

..............................

**NYAN HTUN AUNG**
Union Minister for Transport

For the Government of the Republic of the Philippines:

..................................

**ATTY. CATHERINE JENNIFER P. GONZALES**
Secretary of Transportation and Communications

For the Government of the Republic of Singapore:

..................................

**LUI TUCK YEW**
Minister for Transport

For the Government of the Kingdom of Thailand:

..................................

AIR CHIEF MARSHAL PRAJIN JUNTONG
Minister of Transport

For the Government of the Socialist Republic of Viet Nam:

**សេចក្តីសម្រេច**
**ស្តីពី**
**ការបំពេញបន្ថែមសមាជិកក្រុមការងារ**
**ថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី**
**នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**_

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តបន្ទាយមានជ័យ ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ធូ សុន** | ទីប្រឹក្សារាជរដ្ឋាភិបាល | សមាជិក |
| ២-ឯកឧត្តម | **នៃ ប៉ាត់** | ទីប្រឹក្សារាជរដ្ឋាភិបាល | សមាជិក |
| ៣-ឯកឧត្តម | **ម៉ុង គឹមហេង** | ទីប្រឹក្សារាជរដ្ឋាភិបាល | សមាជិក |
| ៤-ឯកឧត្តម | **យុទ្ធ វិបុល** | ទីប្រឹក្សារាជរដ្ឋាភិបាល | សមាជិក |
| ៥-ឯកឧត្តម | **សើរ ជំនះ** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំយុវជននិងកីឡា ជាសមាជិក | សមាជិក |
| ៦-ឯកឧត្តម | **ប្រាក់ សុភាព** | អគ្គលេខាធិការរង អាជ្ញាធរមីនកម្ពុជា និងជាជំនួយការ ឯកឧត្តមសើរ កុសល | សមាជិក |
| ៧-ឯកឧត្តម | **សុន វ៉ាសិទ្ធ** | ទីប្រឹក្សាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | សមាជិក |
| ៨-លោកជំទាវ | **សើរ សុរិយា** | ទីប្រឹក្សាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ៩-លោកជំទាវ | **សើរ បុប្ផាពេជ្រ** | ទីប្រឹក្សាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ១០-ឯកឧត្តម | **សើរ ឧត្តម** | ជំនួយការ ឯកឧត្តម សើរ កុសល | សមាជិក |
| ១១-លោកស្រី | **ឃិន សោភា** | ជំនួយការ ឯកឧត្តម សើរ កុសល | សមាជិក |
| ១២-លោក | **សើរ បណ្ឌិត** | ជំនួយការ ឯកឧត្តម សើរ កុសល | សមាជិក |
| ១៣-លោក | **ឃិន ច័ន្ទតុលា** | ជំនួយការ ឯកឧត្តម សើរ កុសល | សមាជិក |

**ប្រការ២.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៦

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.០៣៣៨......សហវ.....

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារដោះស្រាយវិវាទពាក់ព័ន្ធការកាន់កាប់ដីរដ្ឋ ដែលស្ថិតក្រោមការប្រើប្រាស់របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង ដោយមន្ត្រី ០២ រូប នៃរតនាគារខេត្តកោះកុង

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៦/៥៥៨ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតែងតាំងមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៥៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារដោះស្រាយវិវាទពាក់ព័ន្ធការកាន់កាប់ដីរដ្ឋ ដែលស្ថិតក្រោមការប្រើប្រាស់របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង ដោយមន្ត្រី ០២ រូប នៃរតនាគារខេត្តកោះកុង ដែលមានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ឈន សុភាព** | អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **មាស សុខសេនសាន** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន | អនុប្រធាន |
| ៣. ឯកឧត្តម **នេត មុន្នី** | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិ និងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៤. ឯកឧត្តម **ម៉ិញ្ញ បានសុទណ្ណអាទិច្ចាស៊ីលា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៥. លោកស្រី **លឹម ឈុនលី** | ប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ៦. លោក **នេព ទិស្លុល** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង | សមាជិក |
| ៧. លោកស្រី **សូច សុរិយា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៨. លោក **ឃិន ពិឆាយ** | ប្រធានរតនាគារខេត្តកោះកុង | សមាជិក |
| ៩. លោក **លី សុខគីម** | ប្រធានការិយាល័យសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១០.លោក **ហ៊ុន ពិសិដ្ឋ** | អនុប្រធានការិយាល័យសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ | សមាជិក ។ |

**ប្រការ២.-**

ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចតទៅ÷

- ជួបប្រជុំ និងដឹកនាំសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយវិវាទដែលកើតមានឡើង
- សិក្សាមូលដ្ឋានផ្លូវច្បាប់ និងលើកយោបល់ជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចាត់វិធានការរដ្ឋបាល និងវិធានការចាំបាច់ដទៃផ្សេងទៀត។
- សិក្សាវាយតម្លៃ និងចរចាជាមួយភាគីពាក់ព័ន្ធ លើប្រាក់ឧបត្ថម្ភគោលនយោបាយ ដែលនឹងត្រូវផ្តល់ជូន
- រៀបចំនិងស្នើសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួង លើគម្រោងថវិកាចំណាយលើប្រាក់ឧបត្ថម្ភគោលនយោបាយ
- ត្រួតពិនិត្យ និងតាមដានការអនុវត្តការប្រគល់ទទួលទីតាំង និងការគ្រប់គ្រងទីតាំងដែលបានដោះស្រាយរួចទៅអាជ្ញាធរកាន់កាប់ដីរដ្ឋវិញ ក្រោយពេលបញ្ចប់ការងារសម្របសម្រួល និងដោះស្រាយវិវាទ
- រាយការណ៍អំពីលទ្ធផលការងារជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.–**

សមាសភាព នៃក្រុមការងារនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំរបស់ក្រុមការងារនេះ តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ៤.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើ-ពន្ធ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.០៤០........សហវ.......

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតថ្នាក់ដឹកនាំអង្គភាពថវិកា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦២១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា

- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៧៩៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ៧៤៧ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៤០ សហវ.ប្រក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ស្តីពីគោលការណ៍និងនីតិវិធីផ្ទៃក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតថ្នាក់ដឹកនាំអង្គភាពថវិកា ដែលសរសេរជាអក្សរកាត់ថា **"ក.ថ.អ."** ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ទី តាយី** | ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ៣. ឯកឧត្តម **រស់ សីលវ៉ា** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៤. ឯកឧត្តម **មាស សុខសេនសាន** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន កសហវ. | សមាជិក |
| ៥. ឯកឧត្តម **គង់ ធីបុល** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៦. ឯកឧត្តម **គុណ ញឹម** | អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៧. ឯកឧត្តម **ចន្ទ្រ ប៊ុនឥន្ទ្រាចុង** | អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |

| | | |
|---|---|---|
| ៨. ឯកឧត្តម **ចន ណារិទ្ធ** | អគ្គនាយកស្តីទី នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ៩. ឯកឧត្តម **ហាច រតនៈ** | អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១០. ឯកឧត្តម **កែវ ចេងចន្ឡន៍** | អគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ១១. ឯកឧត្តម **ឈឹម សារ៉េត** | អគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១២. ឯកឧត្តម **នេត មុន្នី** | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៣. ឯកឧត្តម **ម៉ី ម៉ាន់** | អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ១៤. ឯកឧត្តម **ឆាយ រតនៈ** | អគ្គាធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៥. ឯកឧត្តម **ជា ចុងណា** | អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៦. ឯកឧត្តម **អិន អេម** | នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៧. ឯកឧត្តម **អ៊ុំ សិទ្ធីរ៉ា** | អគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ | សមាជិក |
| ១៨. ឯកឧត្តម **ម៉ែន ធីរុទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | សមាជិក |
| ១៩. ឯកឧត្តម **ស៊ូ សុជាតិ** | អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ២០. ឯកឧត្តម **ស៊ីសុវត្ថិ ជូចចំនួនទៅ** | ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា | សមាជិក។ |

**ប្រការ២.-**

សេចក្តីសម្រេចលេខ ០០៩ សហវ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតថ្នាក់ដឹកនាំអង្គភាពថវិកា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៤៦២ ........ សហវ.......

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលនិងបំពេញបន្ថែមសមាសភាពក្រុមការងារថវិកា ក្រម្រិតផ្ទៃក្នុងអង្គភាពថវិកា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៧៩៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ៧៤៧ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៤០ សហវ.ប្រក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ០០៨ សហវ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតថ្នាក់ដឹកនាំក្រសួង
- បានឃើញសេចក្តីសម្រេចលេខ ០១១ សហវ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតផ្ទៃក្នុងអង្គភាពថវិកា
- បានឃើញសេចក្តីណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ស្តីពីគោលការណ៍និងនីតិវិធីផ្ទៃក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួល និងបំពេញបន្ថែមសមាសភាពក្រុមការងារថវិកា កម្រិតផ្ទៃក្នុងអង្គភាពថវិកា ដែលសរសេរជាអក្សរកាត់ថា **"ក.ថ.ផ."** នៃអង្គភាពថវិកាថ្នាក់កណ្តាល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមមាន អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ, គណៈកម្មការមូលបត្រកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គាធិការដ្ឋាន, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, និងអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដូចខាងក្រោម÷

- អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **ចន ណារិទ្ធ** | អគ្គនាយកស្តីទី | ប្រធាន |
| ២. លោក **គឹម ផល្លា** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **ចាន់ សុគាថា** | អគ្គនាយករង | អនុប្រធាន |

| | | |
|---|---|---|
| ៤. លោក **ឈាន ធណ្ណារិទ្ធ** | ប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ | សមាជិក |
| ៥. លោក **ទូច សុមេធា** | ប្រធាននាយកដ្ឋានស្ថិតិ | សមាជិក |
| ៦. លោក **គង់ រដ្ឋា** | ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន | សមាជិក |
| ៧. លោក **សុខ ខន** | អនុប្រធាននាយកដ្ឋានស្ថិតិ | សមាជិក |
| ៨. លោកស្រី **ស្រស់ សុវត្តិ៍ក្រាកល្យាណនិកា** | ប្រធានការិយាល័យកិច្ចការទូទៅ និងសម្របសម្រួល | សមាជិក។ |

- អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

| | | |
|---|---|---|
| ១. ឯកឧត្តម **ម៉ី វ៉ាន់** | អគ្គនាយក | ប្រធាន |
| ២. លោក **ម៉ូ ច័ន្ទតីរូ** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **អ៊ុន មាត្រា** | ប្រធាននាយកដ្ឋានធានារ៉ាប់រង និងសោធន | សមាជិក |
| ៤. លោក **ណារី សោភល** | ប្រធាននាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ | សមាជិក |
| ៥. លោក **ជួន ថេរ៉ាវ៉ាត** | ប្រធាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | សមាជិក |
| ៦. លោក **នខ ពិសិដ្ឋ** | ប្រធាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន | សមាជិក |
| ៧. លោកស្រី **ទ្រី គីមហេង** | អនុប្រធានលេខាធិការដ្ឋាន | សមាជិក។ |

- គណៈកម្មការមូលបត្រកម្ពុជា

| | | |
|---|---|---|
| ១. ឯកឧត្តម **ស៊ូ សុជាតិ** | អគ្គនាយក | ប្រធាន |
| ២. ឯកឧត្តម **ឈុន សម្បត្តិ** | អគ្គនាយករង | អនុប្រធាន |
| ៣. ឯកឧត្តម **ឌីខ ចន្ថា** | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៤. ឯកឧត្តម **សូរ្យ ប៉ូលែន** | ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ | សមាជិក |
| ៥. លោកបណ្ឌិត **ទិន តត្តី** | ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ | សមាជិក |
| ៦. អ្នកស្រី **ហ៊ា លីតា** | ប្រធានស្តីទីនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ៧. លោកស្រី **នាន បូនី** | ប្រធានស្តីទីនាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ | សមាជិក |
| ៨. លោកស្រី **សុខ សុគន្ធជីវី** | ប្រធានស្តីទីនាយកដ្ឋានកិច្ចការគតិយុត្ត | សមាជិក |
| ៩. លោក **ឈុំ សេរីធុច** | ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង | សមាជិក |
| ១០. លោក **លុយ ហុក** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១១. លោក **អ៊ូច បញ្ញាទិស្សុត** | មន្ត្រីជំនាញ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១២. អ្នកស្រី **កែត សំគាស់** | មន្ត្រីជំនាញ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. កញ្ញា **ជ្រ ស៊្រុំខ** | មន្ត្រីជំនាញ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក។ |

- អគ្គនាយកដ្ឋានពន្ធដារ

| | | |
|---|---|---|
| ១. ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | ប្រធាន |
| ២. លោក **ហ៊ុម ប៊ុនធឿន** | ប្រធាននាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. លោក **អោម ចន** | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ | សមាជិក |
| ៤. លោក **ថែម ចាសនា** | ប្រធាននាយកដ្ឋានត្រួតពិនិត្យ | សមាជិក |
| ៥. លោក **ហ៊ាន ត្រេច** | ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ | សមាជិក |
| ៦. លោក **អេង រតនា** | ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ | សមាជិក |
| ៧. លោក **រ័ត្ន មុនី** | ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស | សមាជិក |
| ៨. លោក **ខួន ទេវី** | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា | សមាជិក |
| ៩. លោក **ស៊ុនលី ជីនី** | ប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ | សមាជិក |
| ១០. លោក **ព្រាប បូណា** | ប្រធានការិយាល័យនៃនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ | សមាជិក |
| ១១. លោក **សួន សុម្ភណៈ** | ប្រធានការិយាល័យនៃនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ | សមាជិក |
| ១២. លោក **ជួរ សៃ** | ប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មសហគ្រាស | សមាជិក |
| ១៣. លោកស្រី **អេង ដាលីន** | ប្រធានការិយាល័យនៃនាយកដ្ឋានត្រួតពិនិត្យ | សមាជិក |
| ១៤. លោក **លី សុតារិទ្ធ** | ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ | សមាជិក |
| ១៥. លោក **អែម សំអាន** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ | សមាជិក |
| ១៦. លោក **អៀង កណ្ណារ៉ា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ | សមាជិក |
| ១៧. លោកស្រី **ពេជ្រ បុប្ផាលក្ខ** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ | សមាជិក |
| ១៨. លោក **ក្រាំង ខៀវ** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មសហគ្រាស | សមាជិក |
| ១៩. លោក **ហេង សុធារិទ្ធ** | អនុប្រធានការិយាល័យនៃនាយកដ្ឋានព័ត៌មានវិទ្យា | សមាជិក |
| ២០. លោក **ជា ម៉ាន់ឌី** | មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ២១. កញ្ញា **អេង សុនិតា** | មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ២២. លោក **ឃិន សាវធី** | មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក។ |

- អគ្គនាយកដ្ឋានថវិកា

| | | |
|---|---|---|
| ១. ឯកឧត្តម **ហាច រតនៈ** | អគ្គនាយក | ប្រធាន |

| | | |
|---|---|---|
| ២. បណ្ឌិត **ញឹម ខេមរា** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **ឡាយ សុខឃៀង** | ប្រធាននាយកដ្ឋានថវិកានីយកម្ម | សមាជិក |
| ៤. លោក **ហេង ស៊ុំឡឿន** | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច | សមាជិក |
| ៥. លោក **ឌី ឆាំថា** | ប្រធាននាយកដ្ឋានវិនិយោគ | សមាជិក |
| ៦. លោក **លឹស ពិនិត្យ** | ប្រធាននាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ៧. លោក **ចណ្ណា ច័ន្ទសុផល** | អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ៨. កញ្ញា **ឈុន ម៉ិនណារី** | អនុប្រធានការិយាល័យព័ត៌មានវិទ្យានិងសរុប | សមាជិក។ |

- អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល

| | | |
|---|---|---|
| ១. ឯកឧត្តម **ម៉ែន ធីរុទ្ធ** | អគ្គនាយក | ប្រធាន |
| ២. លោក **ឈួន សិរីវិទ្ធិ** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **ហ៊ី គុណវឌ្ឍន៍** | ប្រធាននាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ៤. លោក **ឆោ យុទ្ធថា** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី | សមាជិក |
| ៥. លោក **ម៉ាង សុតារ៉ា** | ប្រធាននាយកដ្ឋានគ្រប់គ្រងបំណុល | សមាជិក |
| ៦. លោក **យី សុខធារិទ្ធ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគី | សមាជិក |
| ៧. លោក **ហ៊ុល បុណ្ណាវ័ត្ត** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគី | សមាជិក |
| ៨. លោក **មាស គីមហេង** | អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ៩. លោក **ហាក់ ម៉ិណ្ណារិទ្ធ** | អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ១០. លោកស្រី **ឌិន សារ៉ូ** | ប្រធានការិយាល័យសរុបនិងព័ត៌មានវិទ្យា | សមាជិក។ |

- អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **រស់ សីលវ៉ា** | អគ្គលេខាធិការ | ប្រធាន |
| ២. លោក **យ៉េត ធីរ៉ៃណល** | អគ្គលេខាធិការរង | អនុប្រធាន |
| ៣. លោក **អ៊ុំ យុទ្ធី** | ប្រធានផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៤. លោកស្រី **តិប បូរីតា** | គណនេយ្យករជាន់ខ្ពស់ | សមាជិក |
| ៥. លោកស្រី **សុគន្ធ ចរិយា** | មន្ត្រីថវិកា | សមាជិក |
| ៦. លោកស្រី **ម៉ាង ស៊ីនួន** | មន្ត្រីជំនួយការគណនេយ្យ | សមាជិក។ |

- អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| | | |
|---|---|---|
| ១. ឯកឧត្តម **មាស សុខសេនសាន** | អគ្គលេខាធិការ | ប្រធាន |
| ២. លោក **យ៉េត ធីរ៉ៃណល** | អគ្គលេខាធិការរង | អនុប្រធាន |
| ៣. លោក **គុយ សាធុជ** | អគ្គលេខាធិការរង | អនុប្រធាន |
| ៤. លោក **វ៉ៀម សុចណ្ណា** | អគ្គលេខាធិការរង | អនុប្រធាន |
| ៥. លោក **ឯក ចន្ថា** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. លោក **ម៉ុត សទ្ធារ** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |

| | | |
|---|---|---|
| ៧. លោកស្រី **លឹម ឈុនលី** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៨. លោក **មន្ត ច្រាថ្លា** | ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា | សមាជិក |
| ៩. លោកស្រី **អួន រដ្ឋា** | ប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១០. លោក **អ៊ុក សុផា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ១១. លោកស្រី **ហង់ ស៊ីបូរ៉ែន** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ១២. លោក **សាយ អ៊ាន** | ប្រធានការិយាល័យផែនការថវិកា | សមាជិក |
| ១៣. លោក **ឡុំ ម៉ុងហេង** | អនុប្រធានការិយាល័យផែនការថវិកា | សមាជិក |
| ១៤. លោក **ឈាង ដាមី** | អនុប្រធានការិយាល័យផែនការថវិកា | សមាជិក |
| ១៥. លោក **ស ចាន់ធីរៈ** | អនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ១៦. កញ្ញា **ហួត សំណាង** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ១៧. កញ្ញា **ខេមរិន្ទ រចនា** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ១៨. លោក **ហាក់ រដ្ឋា** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ១៩. កញ្ញា **ស៊ុម ចំនួសុរិយា** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ២០. លោក **ឈឹម ចំនួដារ៉ូ** | មន្ត្រីការិយាល័យផែនការថវិកា | សមាជិក |
| ២១. លោក **ផល សុលី** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ២២. លោក **ហ៊ឹម សុវណ្ណដារ៉ា** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក។ |

- អគ្គាធិការដ្ឋាន

| | | |
|---|---|---|
| ១. ឯកឧត្តម **ឆាយ រតនៈ** | អគ្គាធិការ | ប្រធាន |
| ២. លោក **ឡុញ ប៉ុណ្ណារ៉ា** | អគ្គាធិការរង | អនុប្រធាន |
| ៣. លោក **គង់ ទឡ្ហៈ** | អគ្គាធិការរង | សមាជិក |
| ៤. លោក **ឈឹម សំណាង** | អគ្គាធិការរង | សមាជិក |
| ៥. លោក **ថុង ទុឡ្លី** | ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង | សមាជិក |
| ៦. លោក **ទូច ស្រេង** | ប្រធាននាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុថ្នាក់ជាតិ | សមាជិក |
| ៧. លោក **ជា តារា** | ប្រធាននាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ | សមាជិក |
| ៨. លោក **ទ៉ាន់ ម៉ុនឈឿន** | ប្រធានលេខាធិការដ្ឋាន | សមាជិក |
| ៩. លោក **ហុង គ្រេន** | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១០. លោក **គៅ ទី** | មន្ត្រី | សមាជិក។ |

- អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

| | | |
|---|---|---|
| ១. ឯកឧត្តម **ជា ចុងណា** | អគ្គនាយក | ប្រធាន |
| ២. លោក **គីម្នា សុផុន** | អគ្គនាយករង | អនុប្រធាន |
| ៣. លោកស្រី **ង៉ែត ម៉ូនីឡែន** | អគ្គនាយករង | សមាជិក |

| | | |
|---|---|---|
| ៤. លោក **ឆក សុខុម** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់កណ្តាល | សមាជិក |
| ៥. លោក **ស៊ុំ ផល** | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាន | សមាជិក |
| ៦. លោក **ហ៊ិន តិរុណា** | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់កណ្តាល | សមាជិក |
| ៧. លោកស្រី **សាន សុខនី** | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ៨. លោកស្រី **ហោខ រដ្ឋា** | ប្រធានការិយាល័យសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋានទី១ | សមាជិក។ |

- អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍

| | | |
|---|---|---|
| ១. ឯកឧត្តម **អ៊ុំ សិទ្ធីរ៉ា** | អគ្គនាយក | ប្រធាន |
| ២. លោក **ហ៊ីច បញ្ញាឧត្តម** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **យ៉េន សុគំណា** | អគ្គនាយករង | សមាជិក |
| ៤. លោក **ញាន ទណ្ឌា:** | អគ្គនាយករង | សមាជិក |
| ៥. លោក **ស្រ៊ាង លីមស្រួយ** | ប្រធាននាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ៦. លោក **ចាន់ ឆន់** | ប្រធាននាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុងនិងគ្រប់គ្រងទិន្នន័យ | សមាជិក |
| ៧. លោក **សេខ ទណ្ឌឌី** | ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី១ | សមាជិក |
| ៨. លោក **ស៊ីន់ សេរីវឌ្ឍន:** | ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី២ | សមាជិក |
| ៩. លោក **អ៊ិន ទឡ្ហនា** | ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី៣ | សមាជិក |
| ១០. លោក **ស្រេង ចំរើន** | អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ | សមាជិក។ |

**ប្រការ២.‒**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.‒**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩០៤......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការលើកទឹកចិត្តពន្ធដារចំពោះគ្រឹះស្ថានសិក្សា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារចំពោះវិស័យអប់រំ ដើម្បីជួយជំរុញការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណវុឌ្ឍិខ្ពស់ និងជួយសម្រាលបន្ទុកចំណាយរបស់មាតាបិតា អាណាព្យាបាលសិស្ស និស្សិត។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់នូវយន្តការក្នុងការអនុវត្តពន្ធលើប្រាក់ចំណេញ ពន្ធកាត់ទុក និងអាករលើតម្លៃបន្ថែម សម្រាប់គ្រឹះស្ថានសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសិក្សា ដែលផ្តល់សេវាអប់រំដល់សិស្ស និស្សិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ "គ្រឹះស្ថានសិក្សា" សំដៅដល់ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដែលផ្តល់សេវាសុទ្ធសាធខាងផ្នែកអប់រំ ចាប់ពីថ្នាក់មត្តេយ្យ រហូតដល់ ឧត្តមសិក្សា។ គ្រឹះស្ថានសិក្សា រួមបញ្ចូលផងដែរនូវគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**ប្រការ ៥.- ពន្ធអប្បបរមា ពន្ធលើប្រាក់ចំណេញ និងប្រាក់រំដោះពន្ធលើប្រាក់ចំណេញ**

គ្រឹះស្ថានសិក្សា ត្រូវបានទទួលការអនុគ្រោះដូចខាងក្រោម÷

១- ព្យួរទុកការបង់ពន្ធអប្បបរមា ១% លើផលរបរប្រចាំឆ្នាំ រហូតដល់ដំណាច់ឆ្នាំ២០១៨។

២- ព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ រហូតដល់ដំណាច់ឆ្នាំ២០១៨។

៣- បង់ពន្ធលើប្រាក់ចំណេញតែក្នុងករណីដែលមានប្រាក់ចំណេញប៉ុណ្ណោះ ពីព្រោះគ្រឹះស្ថានសិក្សាទទួលបានការព្យួរទុកពន្ធអប្បបរមា ដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ។

**ប្រការ ៦.- ការផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិត**

ការផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិត ដោយឥតគិតថ្លៃ ឬបញ្ចុះថ្លៃ គឺមិនត្រូវគិតបញ្ចូលជាចំណូលជាប់ពន្ធសម្រាប់គណនាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំទេ។ គ្រឹះស្ថានសិក្សាត្រូវមានឯកសារបញ្ជាក់ច្បាស់លាស់អំពីកម្មវិធីនៃការផ្តល់អាហារូបករណ៍ដោយឥតគិតថ្លៃ ឬបញ្ចុះថ្លៃដល់សិស្ស និស្សិត ដើម្បីជាភ័ស្តុតាងបញ្ជាក់ថាគ្រឹះស្ថានសិក្សាបានផ្តល់អាហារូបករណ៍ពិតប្រាកដមែន។

**ប្រការ ៧.- ពន្ធកាត់ទុក**

គ្រឹះស្ថានសិក្សា ត្រូវអនុវត្តកាតព្វកិច្ចពន្ធកាត់ទុក ដូចខាងក្រោម÷

១- ពន្ធកាត់ទុកលើការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុ ឱ្យដល់អ្នកជាប់ពន្ធនិវាសនជនដែលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស តាមមាត្រា២៥ ថ្មី នៃ ច្បាប់ស្តីពីសារពើពន្ធ÷

ក- ត្រូវបានលើកលែងចំពោះសេវានានារួមទាំងសេវាគ្រប់គ្រងឬពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល ដែលទាក់ទិនផ្ទាល់ទៅនឹងការសិក្សារបស់សិស្ស និស្សិត

ខ- ត្រូវអនុវត្តកាតព្វកិច្ចពន្ធកាត់ទុកចំពោះ÷

- សេវាសាងសង់ វិស្វកម្ម ស្ថាបត្យកម្ម និងសេវាផ្សេងៗទៀត ដែលមិនទាក់ទិនផ្ទាល់នឹងការសិក្សារបស់សិស្ស និស្សិត
- ការជួលចលនឬអចលនទ្រព្យ សួយសារ និងការប្រាក់។

២- ពន្ធកាត់ទុកលើការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុ ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជន តាមមាត្រា២៦ ថ្មី នៃ ច្បាប់ស្តីពីសារពើពន្ធ÷

ក- ត្រូវបានលើកលែងចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា ដែលទាក់ទិនផ្ទាល់នឹងការសិក្សារបស់សិស្ស និស្សិត

ខ- ត្រូវអនុវត្តកាតព្វកិច្ចពន្ធកាត់ទុកចំពោះការប្រាក់ សួយសារ ថ្លៃឈ្នួលនិងប្រាក់ចំណូលផ្សេងៗទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ និងភាគលាភ។

៣- ចំពោះការលើកលែងពន្ធកាត់ទុក ដូចមានចែងក្នុងវាក្យខណ្ឌ ១ នៃកថាខណ្ឌ ១ នៃប្រការនេះ គ្រឹះស្ថានសិក្សាត្រូវមានវិក្កយបត្រត្រឹមត្រូវ ឬមានឯកសារបញ្ជាក់ច្បាស់លាស់អំពីការទូទាត់ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធ ជារៀងរាល់ខែនូវព័ត៌មានអ្នកផ្គត់ផ្គង់សេវា តាមទម្រង់ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

### ប្រការ ៨.- អាករលើតម្លៃបន្ថែម

១- ការផ្គត់ផ្គង់សេវាអប់រំ និងការផ្គត់ផ្គង់ទំនិញឬសេវាផ្សេងទៀតដែលបម្រើឱ្យការអប់រំ រួមទាំងការផ្គត់ផ្គង់ម្ហូបអាហារ និងការស្នាក់នៅរបស់សិស្ស និស្សិត ត្រូវចាត់ទុកថាជាការផ្គត់ផ្គង់មិនជាប់អាករ។ អាករលើធាតុចូលលើទំនិញនិងសេវា ត្រូវបានទិញដោយគ្រឹះស្ថានសិក្សាសម្រាប់ប្រើប្រាស់ក្នុងការផ្គត់ផ្គង់មិនជាប់អាករ មិនត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលទេ ប៉ុន្តែអាចអនុញ្ញាតឱ្យកាត់កងជាចំណាយបាន។

២- ចំពោះគ្រឹះស្ថានសិក្សាដែលមានសកម្មភាពដទៃ ក្រៅពីការផ្គត់ផ្គង់ទំនិញនិងសេវាដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ អាករលើធាតុចូលត្រូវគណនាតាមបទប្បញ្ញត្តិនៃមាត្រា ២៩ ដល់មាត្រា ៤១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម។

### ប្រការ ៩.- ពន្ធអាករដទៃទៀត

គ្រឹះស្ថានសិក្សាត្រូវមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស ព្រមទាំងបង់ពន្ធនិងអាករដទៃទៀតស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ ១០.- ភារកិច្ចរបស់គ្រឹះស្ថានសិក្សា**

វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ការទទួលបានការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងប្រការ៥ ប្រការ៦ ប្រការ៧ និងប្រការ៨ នៃប្រកាសនេះ គ្រឹះស្ថានសិក្សាត្រូវមានកាតព្វកិច្ច ដូចខាងក្រោម÷

- ចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ
- ដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ប្រាក់ពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់
- កាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ ស្របតាមច្បាប់ជាធរមាន
- ដាក់ជូនរដ្ឋបាលសារពើពន្ធនូវរបាយការណ៍សវនកម្មពីស្នងការគណនេយ្យឯករាជ្យ ចំពោះគ្រឹះស្ថានសិក្សា ដែលមានផលរបរប្រចាំឆ្នាំលើសពី ២ ០០០ លានរៀល។

**ប្រការ ១១.- ការបញ្ឈប់ការលើកទឹកចិត្តពន្ធដារ**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីសារពើពន្ធ ការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងប្រកាសនេះអាចនឹងត្រូវបានបញ្ឈប់ ចំពោះគ្រឹះស្ថានសិក្សាណាដែលខកខានមិនបានអនុវត្តតាមខ្លឹមសារ ដូចមានចែងក្នុងប្រការ១០ និងប្រការដទៃទៀតនៃប្រកាសនេះ។

**ប្រការ ១២.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយក នៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់គ្រឹះស្ថានពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងអប់រំ យុវជន និងកីឡា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- សាលារាជធានី ខេត្ត
- ដូចប្រការ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ  សាសនា  ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
**ក្រសួងសេដ្ឋកិច្ច  និង  ហិរញ្ញវត្ថុ**
លេខ...៨០៨.......សហវ.ប្រក

**ប្រកាស**

**ស្ដីពី**

**ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ  នស/រកត/០៩១៣/៩០៣  ចុះថ្ងៃទី២៤  ខែកញ្ញា  ឆ្នាំ២០១៣  ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីសំណើសុំរៀបចំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីជំរុញការអនុវត្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ  ដើម្បីសម្របសម្រួលការអនុវត្ត កម្មវិធីជាតិ យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាលសាធារណៈនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមាសភាព ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម | **មាស សុខសេនសាន** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោក | **យ៉េត ទីណែល** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ៤- លោក | **គង់ ទន្សាន:** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៥- លោក | **ម៉ុត សទ្វារ** | ប្រធាននាយកដ្ឋានបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ៦- លោក | **ហ៊ីម ម៉ិនធឿន** | ប្រធាននាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៧- លោក | **ខៀវ សំអាន** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៨- លោក | **ទ៉ា សុទី** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៩- លោក | **ល័ស ពិនិត្យ** | ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១០- លោក | **ផន ផុន** | អនុប្រធាននាយកដ្ឋានបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន | មន្ត្រីបង្គោល |
| ១១- លោក | **ថន ចាន់ដារ៉ា** | ប្រធានការិយាល័យត្រួតពិនិត្យបុគ្គលិក នៃនាយកដ្ឋានបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន | មន្ត្រីបង្គោល។ |

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ ក្នុងការបំពេញមុខងាររបស់ខ្លួន។

**ប្រការ៣.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ច ដូចខាងក្រោម÷

- ទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័ន ក្នុងការគ្រប់គ្រងនិងដឹកនាំការងារពាក់ព័ន្ធទៅនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ
- ត្រូវរៀបចំសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ក្រសួង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ជូនប្រធានស្ថាប័នជាប្រចាំ
- ត្រូវវាយការណ៍អំពីវឌ្ឍនភាពឱ្យបានទៀងទាត់រៀងរាល់ត្រីមាសទៅលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

- ត្រូវផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈមន្ត្រីបង្គោលក្នុងការស្វែងរកនិងប្រមូលព័ត៌មាន ការរៀបចំផែនការសកម្មភាព ការអនុវត្ត ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការរៀបចំរបាយការណ៍និងបញ្ជូនរបាយការណ៍សង្ខេប នូវសូចនាករដែលទាក់ទងទៅនឹងវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ទៅលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈឬនាយកដ្ឋានជំនាញនៃក្រសួងមុខងារសាធារណៈ។
- មន្ត្រីបង្គោល ត្រូវចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃសម្រាប់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

SECURITIES AND EXCHANGE COMMISSION OF CAMBODIA

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ:......០០៤/១៦.....គ.ម.ក./ប្រ.ក.

**ប្រកាស**
**ស្តីពី**
**ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ**
**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

* * * * *

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ  និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា  ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១  ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Phone : 855-23-885-611  Fax : 855-23-885-622
E-mail : info@secc.gov.kh  Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៣/១១ ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានសមាជិកភាព
- យោងតាមសំណើសុំអនុម័តលើវិធានប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ .០០៤/១៦

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦

ស្តីពី

# វិធានប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.-គោលបំណង

គោលបំណងនៃវិធាននេះ គឺដើម្បីកំណត់អំពីគោលការណ៍នានា រួមមានយន្តការ នីតិវិធី សិទ្ធិ និងកាតព្វកិច្ចដែលចាំបាច់សម្រាប់គ្រប់គ្រងការផ្តល់សន្ទនីយភាពដល់មូលបត្រដែលបានចុះបញ្ជី និងជួញដូរនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា ផ.ម.ក.) និងដែលធ្វើឡើងដោយសមាជិកនៃ ផ.ម.ក. ដែលហៅថា "សមាជិកផ្តល់សន្ទនីយភាព" ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញតិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.-ប្រភេទមូលបត្រដែលត្រូវផ្តល់សន្ទនីយភាព

ការផ្តល់សន្ទនីយភាពដល់មូលបត្រ អាចធ្វើបានចំពោះមូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជីនៅ ផ.ម.ក.។

## ជំពូកទី ២

## ការចុះឈ្មោះ និងការលុបឈ្មោះសមាជិកផ្តល់សន្ទនីយភាព

### ប្រការ ៣.-លក្ខខណ្ឌគុណវុឌ្ឍិ

សមាជិករបស់ ផ.ម.ក. ដែលមានបំណងធ្វើជាសមាជិកផ្តល់សន្ទនីយភាពត្រូវបំពេញលក្ខខណ្ឌគុណវុឌ្ឍិដូចខាងក្រោម÷

- ជាក្រុមហ៊ុនធានាទិញមូលត្រ ឬពាណិជ្ជករមូលបត្រ។

- មានប្រព័ន្ធប្រតិបត្តិការគ្រប់គ្រាន់ និងមានបុគ្គលិកយ៉ាងតិច ១ (មួយ) នាក់ ដើម្បីអនុវត្ត មុខងារផ្តល់សន្ទនីយភាពមូលបត្រ។
- មានយន្តការគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង។

**ប្រការ ៤.-ការចុះឈ្មោះ**

សមាជិកដែលមានបំណងធ្វើជាសមាជិកផ្តល់សន្ទនីយភាព ត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះនៅ ផ.ម.ក. និងបញ្ជាក់ឈ្មោះមូលបត្រដែលត្រូវផ្តល់សន្ទនីយភាព។

ការចុះឈ្មោះនេះមានសុពលភាពរយៈពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការសម្រេចផ្តល់ការចុះឈ្មោះ។ សមាជិកផ្តល់សន្ទនីយភាពដែលមានបំណងបន្តសុពលភាព ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពមក ផ.ម.ក. ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទផុតកំណត់។

ផ.ម.ក. ត្រូវសម្រេចលើការស្នើសុំចុះឈ្មោះយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំពេញលេញ និងត្រូវផ្សព្វផ្សាយជាសាធារណៈភ្លាមអំពីការសម្រេចផ្តល់ការចុះឈ្មោះ។ បន្ទាប់ពីសម្រេចផ្តល់ការចុះឈ្មោះ ផ.ម.ក. ត្រូវផ្តល់ជូនគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) យ៉ាងយូរ ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ នូវបញ្ជីឈ្មោះក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតធ្វើជាសមាជិកផ្តល់សន្ទនីយភាពនេះ។

សមាជិកផ្តល់សន្ទនីយភាព ត្រូវចាប់ផ្តើមអនុវត្តកាតព្វកិច្ចរបស់ខ្លួនមិនឱ្យលើសពីរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រេចផ្តល់ការចុះឈ្មោះ។

សមាជិកផ្តល់សន្ទនីយភាពត្រូវផ្សព្វផ្សាយជាសាធារណៈអំពីឈ្មោះមូលបត្រដែលត្រូវផ្តល់សន្ទនីយភាព និងជូនដំណឹងដល់អតិថិជន រាល់ពេលដែលសមាជិកផ្តល់ប្រឹក្សាលើមូលបត្រនោះ។

**ប្រការ ៥.-ការលុបឈ្មោះ**

សមាជិកផ្តល់សន្ទនីយភាពដល់មូលបត្រមួយ ត្រូវបានលុបឈ្មោះដោយស្វ័យប្រវត្តិក្នុងករណីដែលសមាជិកផ្តល់សន្ទនីយភាពបាត់បង់សមាជិកភាពនៅ ផ.ម.ក. ឬមូលបត្រដែលត្រូវផ្តល់សន្ទនីយភាពនោះត្រូវបានដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ។

សមាជិកផ្តល់សន្ទនីយភាព ដែលមានបំណងលាឈប់ធ្វើជាសមាជិកផ្តល់សន្ទនីយភាពដល់មូលបត្រណាមួយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ ផ.ម.ក. ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទលាឈប់ជាផ្លូវការ។

ផ.ម.ក. ត្រូវផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ និងឯកសារភ្ជាប់ពាក់ព័ន្ធនឹងការជូនដំណឹងលាឈប់ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះ ជូនអគ្គនាយកនៃ គ.ម.ក. ភ្លាម និងត្រូវផ្សព្វផ្សាយជាសាធារណៈភ្លាមៗ អំពីការលុបឈ្មោះសមាជិកផ្តល់សន្ទនីយភាពនេះ។

## ជំពូកទី ៣
## កាតព្វកិច្ច និងការលើកទឹកចិត្ត

**ប្រការ ៦.-កាតព្វកិច្ចពាក់ព័ន្ធនឹងការដាក់បញ្ជាទិញ និងបញ្ជាលក់**

សមាជិកផ្តល់សន្ទនីយភាពត្រូវដាក់និងរក្សាបញ្ជាទិញនិង/ឬលក់ឱ្យមានជាប្រចាំ នៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ដើម្បីធានាថាថ្លៃសម្រាប់ការជួញដូរមានគ្រប់ពេលនៅក្នុងប្រព័ន្ធជួញដូរ និងដើម្បីធានានូវសន្ទនីយភាពមូលបត្រ។

នៅពេលសំណើថ្លៃទិញល្អបំផុតនិង/ឬសំណើថ្លៃលក់ល្អបំផុត មិនមាននៅលើទីផ្សារ ឬមានគម្លាតច្រើនជាង ១០ (ដប់) ឯកតាគម្លាតថ្លៃ សមាជិកផ្តល់សន្ទនីយភាពមានកាតព្វកិច្ចដាក់បញ្ជាលក់និង/ឬបញ្ជាទិញ ដើម្បីធ្វើឱ្យគម្លាតរវាងសំណើថ្លៃទិញនិងសំណើថ្លៃលក់ ត្រឡប់មកនៅតិចជាងឬស្មើ ១០(ដប់) ឯកតាគម្លាតថ្លៃ ក្នុងរយៈពេល ៥ (ប្រាំ)នាទី គិតពីពេលដែលព្រឹត្តិការណ៍នេះកើតមានឡើង។

នៅពេលមានបញ្ជាតែម្ខាងនៅខាងទិញ គម្លាតថ្លៃត្រូវគណនាដោយយកដែនកំណត់ថ្លៃខាងលើដកនឹងសំណើថ្លៃទិញល្អបំផុត ហើយនៅពេលមានបញ្ជាតែម្ខាងនៅខាងលក់ គម្លាតថ្លៃត្រូវគណនាដោយយកសំណើថ្លៃលក់ល្អបំផុតដកនឹងដែនកំណត់ថ្លៃខាងក្រោម។

បញ្ជាទិញ/លក់របស់សមាជិកផ្តល់សន្ទនីយភាព ត្រូវ÷

- មានយ៉ាងតិច ១០០(មួយរយ) ភាគហ៊ុនក្នុងមួយបញ្ជា
- ដាក់នៅក្នុងវគ្គជួញដូរនិរន្តរ៍
- ដាក់ចេញពីគណនីដាច់ដោយឡែកមួយ សម្រាប់សកម្មភាពផ្តល់សន្ទនីយភាពមូលបត្រ។

**ប្រការ ៧.-ការលើកលែងកាតព្វកិច្ចពាក់ព័ន្ធនឹងការដាក់បញ្ជាទិញ និងបញ្ជាលក់**

កាតព្វកិច្ចរបស់សមាជិកផ្តល់សន្ទនីយភាពដែលមានចែងក្នុងប្រការ ៦ ត្រូវបានលើកលែង ក្នុងករណីខាងក្រោម÷

១. គម្លាតរវាងសំណើថ្លៃទិញល្អបំផុតនិងសំណើថ្លៃលក់ល្អបំផុត មានតិចជាងឬស្មើ ១០ (ដប់) ឯកតាគម្លាតថ្លៃ។

២. បរិមាណជួញដូររបស់សមាជិកផ្តល់សន្ទនីយភាពក្នុងមួយថ្ងៃ មានលើសពី ២.០០០ (ពីរពាន់) ភាគហ៊ុន នៃមូលបត្រដែលត្រូវផ្តល់សន្ទនីយភាព។

៣. មានបញ្ជាទិញរបស់អតិថិជនស្ថិតនៅចំដែនកំណត់ថ្លៃខាងលើ ឬបញ្ជាលក់របស់អតិថិជនស្ថិតនៅចំដែនកំណត់ថ្លៃខាងក្រោម។

៤. មានការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យថ្លៃមូលបត្រដែលត្រូវផ្តល់សន្ទនីយមានភាពប្រែប្រួលមិនប្រក្រតី។ ក្នុងករណីនេះ សមាជិកផ្តល់សន្ទនីយភាពត្រូវស្នើសុំជាលាយលក្ខណ៍អក្សរមក ផ.ម.ក. ដើម្បីផ្តល់ការអនុញ្ញាតលើកលែងកាតព្វកិច្ច។

៥. ដំណើរខុសប្រក្រតីនៃប្រព័ន្ធជួញដូររបស់ ផ.ម.ក.។

៦. មូលបត្រដែលត្រូវផ្តល់សន្ទនីយភាព ត្រូវបានផ្អាកឬព្យួរពីការជួញដូរ។

៧. សមាជិកភាពរបស់សមាជិកផ្តល់សន្ទនីយភាពនៅ ផ.ម.ក. ត្រូវបានព្យួរ។

**ប្រការ ៨.-ការជូនដំណឹងស្តីពីការមិនអាចអនុវត្តកាតព្វកិច្ច**

សមាជិកផ្តល់សន្ទនីយភាព ត្រូវជូនដំណឹងមក ផ.ម.ក. ភ្លាម ក្នុងករណីមិនអាចអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងការដាក់បញ្ជាទិញ និងបញ្ជាលក់ និងក្នុងករណីអាចចាប់ផ្តើមអនុវត្តកាតព្វកិច្ចឡើងវិញបាន។ ផ.ម.ក. ត្រូវជូនដំណឹងជូន គ.ម.ក. ករណីសមាជិកផ្តល់សន្ទនីយភាពមិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

**ប្រការ ៩.-ការលើកទឹកចិត្ត**

សមាជិកផ្តល់សន្ទនីយភាពទទួលបានការលើកលែងថ្លៃសេវារបស់ ផ.ម.ក. (ថ្លៃសេវាជួញដូរមូលបត្រ ថ្លៃសេវាជាត់ទាត់និងទូទាត់មូលបត្រ និងថ្លៃសេវានៃការផ្ទេរមូលបត្ររវាងគណនី) ។

ផ.ម.ក. អាចសម្រេចផ្តល់ការលើកទឹកចិត្តផ្សេងទៀតដល់សមាជិកផ្តល់សន្ទនីយភាព នៅពេលដែល ផ.ម.ក. យល់ឃើញថាចាំបាច់ដើម្បីជំរុញសកម្មភាពផ្តល់សន្ទនីយភាពនេះបន្ថែមទៀត។

## ជំពូកទី ៤
## ការតាមដាន និងការហាមឃាត់

**ប្រការ ១០.-ការតាមដានលើសមាជិកផ្តល់សន្ទនីយភាព**

ផ.ម.ក. ត្រូវតាមដានជាទៀងទាត់លើសកម្មភាពនៃការផ្តល់សន្ទនីយភាពនេះ ដើម្បីធានានូវការជួញដូរស្មោះត្រង់នៅលើទីផ្សារ និងត្រូវរាយការណ៍ជូនអគ្គនាយកនៃ គ.ម.ក. ក្នុងករណីដែលមានភាពមិនប្រក្រតីនៃសកម្មភាពផ្តល់សន្ទនីយភាពមូលបត្រនេះ។

ផ.ម.ក. ត្រូវវាយតម្លៃគុណភាពការងាររបស់សមាជិកផ្តល់សន្ទនីយភាពជាជារៀងរាល់ត្រីមាស ដោយពិនិត្យលើលក្ខណៈនៃការចូលរួមចំណែកធ្វើឱ្យសន្ទនីយភាពទីផ្សារប្រសើរឡើងដូចជា÷ ភាពប្រសើរឡើងនៃគម្លាតថ្លៃ ភាពពេញលេញនៃការបំពេញកាតព្វកិច្ច និងការដាក់បញ្ជាទាន់ពេលវេលាជាដើម។ ក្នុងករណីដែលសមាជិកផ្តល់សន្ទនីយភាព ខកខានអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងរយៈពេល ២ (ពីរ) ត្រីមាសជាប់គ្នា ផ.ម.ក. អាចបញ្ឈប់ ឬផ្អាកសកម្មភាពរបស់សមាជិកផ្តល់សន្ទនីយភាពនោះសម្រាប់រយៈពេល ១ (មួយ) ឆ្នាំ យ៉ាងតិច។ ផ.ម.ក. ត្រូវផ្តល់ជូន គ.ម.ក. នូវរបាយការណ៍លទ្ធផលនៃការវាយតម្លៃការងារលើសមាជិកផ្តល់សន្ទនីយភាព និងឯកសារពាក់ព័ន្ធ យ៉ាងយូរ ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់ការវាយតម្លៃ។

**ប្រការ ១១.-ការហាមឃាត់**

